ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី

លេខ៖ ១៤០

ចុះថ្ងៃទី០២-៣-២០២០

សាលដីកា

លេខ៖ ១៧ក្រII«វ»

ចុះថ្ងៃទី ២៤-៧-២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

**លោក** [redacted] **ប្រធានក្រុមប្រឹក្សា**

**ឯកឧត្តម** **ចៅក្រុមប្រឹក្សា**

**លោកស្រី** **ចៅក្រុមប្រឹក្សា**

**ក្រឡាបញ្ជីសវនាការ**

**លោកស្រី ហ៊ិន សុគន្ធា**

ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅសំណុំរឿងរដ្ឋប្បវេណីលេខ ១៤០ ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០២០ ដែលមាន ៖

**<u>ដើមចោទ</u>** ÷

-ឈ្មោះ [redacted] **គឹមសេង** ភេទប្រុស អាយុ៦៨ឆ្នាំ មុខរបរនៅផ្ទះ ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted]។

មានលោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**<u>សមាចុងចម្លើយ</u>** ÷

១-ឈ្មោះ [redacted] **សំអូក** ភេទស្រី អាយុ៦៩ឆ្នាំ មុខរបរ កសិករ។

២-ឈ្មោះ [redacted] **ម៉ាន** ភេទប្រុស អាយុ៦៧ឆ្នាំ មុខរបរ កសិករ។

៣-ឈ្មោះ [redacted] ភេទស្រី អាយុ៤៥ឆ្នាំ មុខរបរ កសិករ។

៤-ឈ្មោះ [redacted] **សម្បត្តិ** ភេទប្រុស អាយុ៤៥ឆ្នាំ មុខរបរ កសិករ។

៥-ឈ្មោះ [redacted] **ខុន** ភេទប្រុស អាយុ៦២ឆ្នាំ មុខរបរ កសិករ។

៦-ឈ្មោះ [redacted] **ចន្ធី** ភេទស្រី អាយុ៥៥ឆ្នាំ មុខរបរ កសិករ។

៧-ឈ្មោះ [redacted] **ឆន** ភេទប្រុស អាយុ៤៨ឆ្នាំ មុខរបរ យោធិន។

៨-ឈ្មោះ [redacted] **ដេន** ភេទស្រី អាយុ៤៧ឆ្នាំ មុខរបរ កសិករ ។

ទីលំនៅបច្ចុប្បន្ន ភូមិកងតាណឹងទី១ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។





Scanned with CamScanner

**កម្មវត្ថុបណ្តឹង ៖**

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖**

១-បញ្ជាក់ថាឈ្មោះ [redacted] គឹមសេង មានសិទ្ធិកាន់កាប់ ឬកម្មសិទ្ធិ និងប្រគល់ដីចំនួន ០២ កន្លែង (ទំហំ ២៧០០ម² និងទំហំ ២២៥០ម²) ស្ថិតនៅភូមិកងតាណឹងទី១ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម ដែលសហចុងចម្លើយកំពុងរស់នៅ។

២-បង្គាប់ឲ្យសហចុងចម្លើយរុះរើសំណង់ និងចាកចេញពីទីតាំងដីទាំងពីរខាងលើ។

៣-បង្គាប់ឲ្យសហចុងចម្លើយម្នាក់ៗ (មួយគ្រួសារ) សងសំណងជម្ងឺចិត្ត ការខាតពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ១០.០០០ (មួយម៉ឺន)ដុល្លារអាមេរិក។

**ខ្លឹមសារនៃបណ្តឹងតបដែលដើមបណ្តឹងតបទាមទារឲ្យតុលាការចេញ ៖**

-មិនព្រមប្រគល់ដីទំនាស់ទាំង ០២ កន្លែង (ទំហំ ២៧០០ម² និងទំហំ ២២៥០ម²) នេះ ឲ្យទៅដើមចោទទេ ព្រោះដីនេះ ពួកខ្លួនបានចូលទៅរស់នៅ កាន់កាប់ បង្កបង្កើនផល តាំងពីឆ្នាំ ១៩៧៩ មក។

**អង្គហេតុ និងចំណុចវិវាទ**

ដើមចោទបានទាមទារសិទ្ធិកាន់កាប់ ឬកម្មសិទ្ធិនៅលើដីទំហំ ចំនួន ០២កន្លែង (ទំហំ ២៧០០ម² និងទំហំ ២២៥០ម²) ស្ថិតនៅភូមិកងតាណឹងទី១ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម ដែលសហចុងចម្លើយកំពុងរស់នៅ និងទាមទារឲ្យសហចុងចម្លើយរុះរើសំណង់ និងចាកចេញពីទីតាំងដីទាំងពីរខាងលើ ដោយអះអាងថា ដីទាំងពីរកន្លែងនេះ គឺជាដីកេរតាំងពីជំនាន់ឪពុកម្តាយខ្លួន ពោលគឺមុនសម័យប៉ុលពត មុនឆ្នាំ១៩៧៥ មកម្ល៉េះ និងផ្អែកទៅលើពាក្យស្នើសុំកាន់កាប់ដីទាំង ០២កន្លែង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៩។ រហូតមកដល់សម័យប៉ុលពតដួលរលំ នៅឆ្នាំ១៩៧៩ ដោយមានភាពឈឺចាប់នឹងការបាត់បង់សាច់ញាតិ ដើមចោទមិនបានចូលមករស់នៅ និងកាន់កាប់នៅលើដីរបស់ខ្លួនឡើយ ដោយបានទៅរស់នៅខាងប្រពន្ធនៅភ្នំពេញ ហើយដីទំនាស់ទាំង០២កន្លែង ក៏ត្រូវបានសហចុងចម្លើយនាំគ្នាមករស់នៅ និងដាំដំណាំជាលក្ខណៈគ្រួសារខ្លះៗ រហូតមកដល់បច្ចុប្បន្ននេះ (ចុងចម្លើយខ្លះក៏បន្តពីឪពុកម្តាយខ្លួន)។ ប៉ុន្តែជារៀងរាល់ឆ្នាំដើមចោទតែងតែមកធ្វើបុណ្យឲ្យឪពុកម្តាយរបស់ខ្លួន។

**បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ៖ ២៨៦ "គ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម ដែលមានខ្លឹមសារសម្រេចសេចក្តីដូចខាងក្រោម ៖**

១/.ច្រានចោលការប្តឹងទាមទាររបស់ដើមចោទឈ្មោះ [redacted] គឹមសេង។

២/.រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់រួច។ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៣/.សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ ចំពោះមុខដើមចោទ និងចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩។



Scanned with CamScanner

**-បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០២ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] គីមសេង ប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៨៦ "គ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**<u>នាពេលនាញហេតុផលដោយផ្ទាល់មាត់</u>**

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបអង្គហេតុ ។

-ដើមចោទឈ្មោះ [redacted] **គីមសេង** (វត្តមាន) ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ (វត្តមាន) ។

-សហចុងចម្លើយឈ្មោះ [redacted] **សំអូក**, ឈ្មោះ [redacted] **ម៉ារ៉ាន**, ឈ្មោះ [redacted] **រី**, ឈ្មោះ [redacted] **សម្បត្តិ**, ឈ្មោះ [redacted] **ខុន**, ឈ្មោះ [redacted] **ចន្ធី**, ឈ្មោះ [redacted] **ឆន** និងឈ្មោះ [redacted] **ដេន** (វត្តមាន) ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ (វត្តមាន) ។

<u>ការអះអាងរបស់ភាគីដើមចោទ</u> (ដើមបណ្តឹងឧទ្ធរណ៍)

-ដើមចោទឈ្មោះ [redacted] **គីមសេង** បានធ្វើការអះអាងថា ៖ ដីទាំងពីរកន្លែងដែលមានទំហំ ២៧០០ម៉ែត្រការ៉េ និងទំហំ ២២៥០ម៉ែត្រការ៉េ ដែលខ្លួនកាន់កាប់នេះគឺខ្លួនមានឯកសារពាក្យស្នើសុំកាន់កាប់ដីធ្លី ធ្វើនៅឆ្នាំ១៩៨៩។ ខ្លួនពុំបានសាងសង់អ្វីនោះទេ តែខ្លួនបានទៅធ្វើបុណ្យឪពុកនៅលើដីហ្នឹង នៅឆ្នាំ១៩៨១។ កន្លងមកខ្លួនបានទៅធ្វើបុណ្យនៅវត្ត ហើយបានចូលទៅលេងនៅដីទាំងពីរហ្នឹងរហូត ។ ពេលខ្លួនទៅធ្វើបុណ្យសពឪពុកខ្លួន គឺពុំទាន់មានអ្នកណានៅលើដីហ្នឹង ហើយខាងចុងចម្លើយបានមកនៅឆ្នាំ១៩៨៥ ហើយខ្លួនពុំបានឲ្យនៅលើដីហ្នឹងទេ គឺគាត់មកដោយខ្លួនឯង។ ខ្លួនធ្លាប់ប្រាប់ឲ្យគាត់ចេញដែរ តែពួកគាត់អត់ព្រមចេញ ខ្លួនក៏នៅតែប្រាប់ទៀត តែដោយយល់ថាជាបងប្អូន ។ ដីដែលឈ្មោះ [redacted] សំអូក រស់នៅនេះ គឺអត់ទាន់មានក្រដាសស្នាមអ្វីនោះទេ។ ខ្លួនបានប្តឹងទាមទារដីនេះនៅឆ្នាំ២០១៨។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ កូនក្តីខ្លួនបានគ្រប់គ្រងកាន់កាប់ទីតាំងទាំងនេះតាមរយៈការមកគាស់សពឪពុក និងបងប្អូនធ្វើបុណ្យ មកលក់ផ្ទះលើដីនោះ និងធ្វើបុណ្យទាន ជារៀងរាល់ឆ្នាំ មកដល់ពេលនេះ ជាពិសេសមានពាក្យសុំកាន់កាប់លើដីទាំងពីរទៀត មិនបានបោះបង់ចោលនោះទេ។ ចំពោះការរស់នៅរបស់សហចុងចម្លើយលើដីទាំងនេះ ពួកគេទាំងអស់សុទ្ធតែដឹងថា ដីនេះជាដីកេរ្តិ៍របស់ឪពុកម្តាយកូនក្តីខ្លួន ជាពិសេសកូនក្តីខ្លួនមិនបានបោះបង់ដូចរៀបរាប់ខាងលើ ថែមទាំងមានពាក្យសុំកាន់កាប់លើដីទាំងពីរទៀត។ ចំណែកឈ្មោះ [redacted] ខុន បានធ្វើកិច្ចសន្យាជាមួយសាលាឃុំថា នឹងប្រគល់ដីនេះអោយម្ចាស់គេវិញពេលម្ចាស់គេមក ដែលករណីនេះបានផ្តល់ចម្លើយដោយសាក្សីលោក [redacted] គឺ ជាអតីតមេឃុំ។ ចំណែកឈ្មោះ [redacted] រី ក៏បានសុំទិញដីនេះពីកូនក្តីខ្លួនដែរ។ ពួកគេត្រូវបានកូនក្តីខ្លួនអនុញ្ញាតឲ្យរស់នៅជាបណ្តោះអាសន្ន ដោយយល់ជាបងប្អូន ហើយក្រោយមក ត្រូវហៅទៅនិយាយគ្នាអោយចាក



Scanned with CamScanner

ចេញជាច្រើនលើកដែរ ប៉ុន្តែពួកគេបដិសេធ។ នៅក្នុងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់កូនក្តីខ្លួន សម្រាប់ដីទី១ បញ្ជាក់ថា ដីនេះមានទំហំចំនួន ២៧០០ម៉ែត្រការ៉េ ចំណែកពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់សហចុងចម្លើយឈ្មោះ [redacted] ខុន បញ្ជាក់ថា ដីនោះមានទំហំចំនួន ២២៥០ម៉ែត្រការ៉េ ទៅវិញ។ ដូច្នេះ ពត៌មានពីទំហំដីក្នុងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់សហចុងចម្លើយឈ្មោះ [redacted] ខុន មានវិការៈ ឬមានបញ្ហា។ នៅក្នុងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់កូនក្តីខ្លួនសម្រាប់ដីទី១ មេភូមិឈ្មោះ [redacted] រឿន បានបញ្ជាក់ថា ដីនេះពិតជារបស់កូនក្តីខ្លួន បានកាន់កាប់ពិតមែន ចំណែកពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់សហចុងចម្លើយឈ្មោះ [redacted] ខុន មេភូមិឈ្មោះ [redacted] រឿង បានបញ្ជាក់ថា ស្នាមមេដៃនេះពិតជារបស់គាត់មែន។ ដូច្នេះ ការបញ្ជាក់របស់លោក [redacted] រឿន ក្នុងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់កូនក្តីខ្លួនបញ្ជាក់ពីការកាន់កាប់ពិតប្រាកដ និងច្បាស់លាស់ ជាងបញ្ជាក់ថា វាជាស្នាមមេដៃរបស់ឈ្មោះ [redacted] ខុន។ ខ្លួនស្នើសុំរក្សាសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ទុកជាបានការដដែល និងសំណូមពរ ក្រុមប្រឹក្សាជំនុំជម្រះ សម្រេចលុបចោល សាលក្រមលេខ ២៨៦ "គ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម និងសម្រេចតាមការទាមទារក្នុងពាក្យបណ្តឹងរបស់កូនក្តីខ្លួន តាមបញ្ញត្តិច្បាប់ជាធរមាន។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ចំណុចនេះឃើញថា រឿងក្តីនេះគឺជាទំនាស់ដីធ្លីរវាងកូនក្តីខ្លួន ជាមួយសហចុងចម្លើយ ទាក់ទងទៅនឹងបញ្ហាដីធ្លី ទី១ ដោយសារតែភាគី [redacted] ខុន គាត់បានធ្វើការស្នើសុំរស់នៅជាបណ្តោះអាសន្ន លើដីរបស់កូនក្តីខ្លួន។ ឈ្មោះ [redacted] ខុន ដែលបានស្នើសុំរស់នៅជាបណ្តោះអាសន្នលើដីនេះ គឺមានសាក្សីឈ្មោះ [redacted] ជាអតីតមេឃុំ ហើយគាត់បានឆ្លើយរួចហើយ។ ការស្នើសុំកាន់កាប់របស់គាត់គឺខុសទីតាំងដី និងទំហំ គាត់ពុំបានស្គាល់ដីនេះច្បាស់ទេ ដោយសារគាត់មិនមែនជាម្ចាស់កម្មសិទ្ធិ ហើយកូនក្តីខ្លួនគាត់ស្គាល់ច្បាស់ដោយសារគាត់ជាម្ចាស់ដីស្របច្បាប់។ ជាចុងក្រោយ ស្នើសុំលោកចៅក្រមសម្រេចលុបចោលសាលក្រមលេខ ២៨៦-"គ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម។

<u>ការអះអាងរបស់ភាគីសហចុងចម្លើយ</u> (ចុងបណ្តឹងឧទ្ធរណ៍)

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ យោងច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ៧ របក កម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់នោះទេ កូនក្តីខ្លួនរស់នៅកាន់កាប់គ្រប់គ្រង និងអាស្រ័យផល លើដីទំនាស់ដែលមានទីតាំងស្ថិតនៅភូមិកងតាណឹងទី១ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម តាំងពីឆ្នាំ១៩៧៩ រហូតដល់បច្ចុប្បន្នដែលមានប្រជាពលរដ្ឋរស់នៅទីនោះដឹងឮជាសាធារណៈ និងអាជ្ញាធរទទួលស្គាល់ទៀតផង ដោយពុំមានការជំទាស់ពីជនណាម្នាក់ឡើយ។ ជាក់ស្តែងកូនក្តីខ្លួនបានដាំដំណាំ និងបង្កបង្កើនផល និងសង់ផ្ទះលើដីនោះទៀតផង។ យោងតាមមាត្រា ៣០ នៃច្បាប់ភូមិបាល កូនក្តីខ្លួនអាចក្លាយទៅជាកម្មសិទ្ធិករស្របច្បាប់តាមរយៈលទ្ធកម្មនៃកម្មសិទ្ធិដោយអាជ្ញាយុកាល និង



Scanned with CamScanner

មាត្រា ៣៨ កាន់កាប់ដោយពិតប្រាកដ គ្មានហិង្សាដោយមានការដឹងឮជាសាធារណៈ និងសុចរិត។ យោងតាមមាត្រា ១៦២ កូនក្តីខ្លួនមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីក្លាយទៅជាម្ចាស់កម្មសិទ្ធិករ ព្រោះកូនក្តីខ្លួនបានកាន់កាប់ដីនេះជាងរយៈពេល ៤០ឆ្នាំហើយ។ ផ្អែកតាមមាត្រានេះ កថាខណ្ឌទី១ រយៈពេលនៃកាន់កាប់ ២០ឆ្នាំ និងកថាខណ្ឌទី២ រយៈពេលនៃកាន់កាប់ ១០ឆ្នាំ គឺកូនក្តីខ្លួនបានកាន់កាប់លើសពីរយៈពេលនេះទៀត។ យោងតាមមាត្រា ២៣៣ នៃក្រមរដ្ឋប្បវេណី ក៏បានការពារលើភោគីផងដែរ។ ហេតុដូចនេះ កូនក្តីខ្លួនបានកាន់កាប់ដីទំនាស់នេះតាំងពីមិនទាន់ចេញច្បាប់ភូមិបាល ដែលអាចអនុវត្តសិទ្ធិទាមទារលើដីនេះបាន ។ ផ្ទុយទៅវិញ ដើមចោទពុំមានឯកសារបញ្ជាក់ថា អនុញ្ញាតឲ្យកូនក្តីខ្លួនរស់នៅជាបណ្តោះអាសន្ននោះទេ ហើយដើមចោទក៏បានអះអាងថាខ្លួនពុំបានរស់នៅលើដីទំនាស់នោះទេ។ ដូចនេះ ស្នើសុំលោកប្រធានសម្រេចច្រានចោលការទាមទាររបស់ដើមចោទ។

## <u>សាលាឧទ្ធរណ៍ភ្នំពេញ</u>

## <u>យល់ឃើញថា</u> ÷

១/.បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] គឺមសេង ប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៨៦"គ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ក្រុមប្រឹក្សាជំនុំជម្រះ លើកយករឿងនេះដើម្បីទាញហេតុផលដោយផ្ទាល់មាត់បាន យោងតាមមាត្រា ៨៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២/.តាមលទ្ធផលនៃនីតិវិធីទាញហេតុដោយផ្ទាល់មាត់ឃើញថា ៖ ដីទំនាស់ចំនួន ០២ កន្លែង (ទំហំ ២៧០០ម$^2$ និងទំហំ ២២៥០ម$^2$) ស្ថិតនៅភូមិកងតាណឹងទី១ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររវាងដើមចោទ និងសហចុងចម្លើយនេះ គឺជាប្រភេទដីដែលពុំទាន់មានប័ណ្ណសំគាល់សិទ្ធិនៅឡើយ។

-ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា តាមប្រកាសអន្តរក្រសួងលេខ ០២ ប្រករ.ប៣ ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណកម្មការសុរិយោដី ពាក់ព័ន្ធនឹងវិវាទដីធ្លី គ្រង់ចំណុចប្រការ ១ បានចែងថា "វិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីសុរិយោដី គឺដីធ្លីដែលពុំទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទ ចេញដោយរដ្ឋបាល សុរិយោដី ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី" ។ ប្រការ២ បានចែងថា "តុលាការគ្រប់ខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលបណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចគណៈកម្មការសុរិយោដី ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ"។ ចំណុចនេះ បញ្ជាក់ឲ្យឃើញថា តុលាការគឺពុំមានសមត្ថកិច្ចក្នុងការដោះស្រាយសំណុំរឿងទាំងឡាយណាដែលទាក់ទងទៅនឹងវិវាទដីធ្លីដែលពុំទាន់មានប័ណ្ណសំគាល់សិទ្ធិ នៅក្រោយពេលប្រកាសអន្តរក្រសួងលេខ ០២ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណកម្មការសុរិយោដី ពាក់ព័ន្ធនឹងវិវាទដីធ្លី នេះចូលជាធរមាន ឡើយ។



Scanned with CamScanner

៣/.សាលក្រមរដ្ឋប្បវេណីលេខ ២៨៦"គ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម សម្រេចមកនេះពុំមានលក្ខណៈត្រឹមត្រូវឡើយ ដែលគប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចលុបចោល និងបង្វិលសំណុំរឿងនេះ ទៅគណៈកម្មការសុរិយោដីខេត្តកំពង់ចាម ដើម្បីដោះស្រាយជាសមត្ថកិច្ច ។

៤/.អនុលោមតាមមាត្រា ៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១/.លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ២៨៦ "គ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម។

២/.បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១៥០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ ទៅគណៈកម្មការសុរិយោដីខេត្តកំពង់ចាម ដើម្បីចាត់ការសមត្ថកិច្ច។

៣/.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

សាលដីកានេះប្រកាសជាសាធារណៈថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ។

បើកសិទ្ធិប្តឹងសាទុក្ខរយៈពេល០១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា៖ [redacted] | ហត្ថលេខា៖ [redacted] | ហត្ថលេខា៖ [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសៅរ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ពស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ៧ ឆ្នាំ២០២០

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]